# ពិធីកោរជុកនៅខេត្តកំពង់ចាម ៖ ដង្ហើមចុងក្រោយត្រដររស់?

ស៊ុន ចាន់ដឹប
*សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ*

កំណាត់ហេតុខាងក្រោមនេះ ខ្ញុំពុំមែនធ្វើឡើងក្នុងបំណងរៀបរាប់ថា នៅខេត្តកំពង់ចាម កិច្ចពិធីថ្លង់វ័យក្មេងមុនជំទង់ហៅថា "កោរជុក" គេធ្វើយ៉ាងដូចម្ដេចទេ។ ទោះជានិយាយពីដំណើរកិច្ចនោះត្រួសៗខ្លះ ក៏នេះពុំមែនជាបំណងសំខាន់ដែរ តែគឺជាការសង្កេតថាប្រពៃណីមួយដែលទើបនឹងបាត់បង់ទៅប៉ុន្មានទសវត្សនេះ ហាក់ដូចជាកំពុងត្រដរខ្យល់ឡើងវិញប្រឹងរស់ទៀត។ រីឯសំនួរថាតើជាដង្ហើមចុងក្រោយពិតប្រាកដ ឬក៏ប្រហែលមានវាសនារស់ឡើងវិញនោះ ខ្ញុំក៏ពុំអាចស្មានត្រូវដែរ។ សង្គមវិទូ ឬនរវិទូគួរយកឧទាហរណ៍ដែលខ្ញុំនឹងបង្ហាញនេះជាមេរៀន ឬជាប្រធានបទពិចារណា។ ការប្រៀបធៀបក៏មិនអត់សោះដែរ គឺខ្ញុំនឹងធ្វើការប្រៀបធៀបត្រួសៗខ្លះជាមួយប្រពៃណីកោរជុកនៅតំបន់អង្គរ ដោយផ្អែកលើឯកសារដែលលោកគ្រូ អាំង ជូលាន ព្រមទាំង "ក្រុមសិក្សាសង្គម" ដែលអតីតនាយកដ្ឋានវប្បធម៌ស្រាវជ្រាវនៃអាជ្ញាធរអប្សរាធ្លាប់រៀបចំមក។ ហេតុអ្វីក៏ចាំបាច់ប្រៀបធៀប? គឺដើម្បីដឹងថា កាលដែលគេនៅធ្វើជាប្រក្រតីនោះ ប្រពៃណីកោរជុកនៅខេត្តកំពង់ចាមមានលក្ខណៈរបស់ខ្លួនផ្ទាល់ ខុសពីតំបន់ខាងជើង ឬមួយការកោរជុកនៅប្រទេសកម្ពុជាទាំងមូលចេញមកពីគម្រូតែមួយ។ ខ្ញុំសូមបញ្ជាក់ថា "កំពង់ចាម" ដែលនិយាយកាត់នេះ តាមពិតសំដៅទៅលើតែម្តុំភូមិមួយចំនួនដែលសព្វថ្ងៃជាចំណុះស្រុកបាធាយប៉ុណ្ណោះ គឺកន្លែងដែលខ្ញុំធ្លាប់ទៅស្រាវជ្រាវញឹកញាប់ ដោយសារអ្នកស្រុកនៅទីនោះនៅកាន់ប្រពៃណីច្រើន។

## រំលឹកខ្លះៗពីការកោរជុកនៅតំបន់អង្គរ[១]

កោរជុកជាពិធីឆ្លងវ័យក្មេងស្រីប្រុសចាប់ពីអាយុ ១០ឆ្នាំទៅទល់មុនពេញវ័យ។ យ៉ាងណាក៏ត្រូវកោរផ្តាច់មុនពេញកម្លោះឬក្រមុំ។ ប្រុសពិបាកកំណត់បន្តិច បើស្រីវិញ ដែលហៅថាក្រមុំនោះ គឺគេគិតពីពេលដែលចាប់ផ្តើមមានរដូវ។ ដូច្នេះយ៉ាងយូរគេឲ្យកោរត្រឹមអាយុ១៣ឆ្នាំ បើជ្រុលមានរដូវហើយ នៅតំបន់ខាងជើងគេហៅថា "បរាជិក"[២]។ រីឯថាចាប់ពីអាយុ១០ឆ្នាំនោះ ក៏គ្រាន់តែជាគោលទេ តាមការជាក់ស្តែង គឺឲ្យតែមានក្មេងម្នាក់ពីរកោរត្រឹមត្រូវតាមអាយុនោះ ក្មេងឯទៀតដែលនៅខ្ចីជាង អាយុក្រោម១០ឆ្នាំមកកោរជាមួយក៏មិនអ្វីដែរ គ្រាន់តែគេពុំឲ្យឆ្លងកិច្ចមួយហៅថា "ដេកអង្កររាប"។ និយាយឲ្យខ្លីមក ពិធីកោរជុក[៣] ជាពិធីឆ្លងវ័យក្មេងស្រីប្រុសឲ្យប្រុងប្រៀបខ្លួនទៅរក "ពេញវ័យ"។

## ទេសកាល

ពិធីកោរជុកពីរកន្លែងដែលខ្ញុំបានឃើញនៅខែមិនានិងខែឧសភា ឆ្នាំ២០០៨កន្លងទៅនេះ ធ្វើឡើងក្នុងទេសកាលពិសេសមួយ ពុំមែនដោយប្រក្រតីពេញលេញទេ ដូចមានបង្ហើបបន្តិចពីលើមក។ ប្រជាជននៅភូមិមួយចំនួនក្នុងស្រុកបាធាយ, ខេត្តកំពង់ចាម, នៅរក្សាប្រពៃណីច្រើន។ បើពោលពីឆ្លងវ័យជាឧទាហរណ៍ គឺមានក្មេងស្រីជំទង់ចូលម្លប់រាល់ឆ្នាំនៅឡើយ។ ដោយសារធ្លាប់មើលគេចូលម្លប់ច្រើនលើកច្រើនគ្រានេះហើយ បានជាខ្ញុំមានទំនាក់ទំនងរាប់អានគ្នាច្រើនជាមួយអ្នកស្រុកព្រមទាំងអាចារ្យនានាជាអ្នកធ្វើកិច្ច។ ថ្ងៃមួយខ្ញុំបានសួរជីកឫសជីកគល់ទៅលោកអាចារ្យពីទំនៀមកោរជុក ទើបគាត់ប្រាប់ថាទើបនឹងខានធ្វើដោយសារសង្គ្រាមប៉ុន្មានទសវត្សមុននេះ តែនៅសល់ក្បួនក្នុងក្រាំង បើធ្វើទៀតប្រហែលធ្វើបាន។ ខ្ញុំក៏និយាយចេញពីចិត្តស្មោះ លើកតម្លៃការរក្សាប្រពៃណីទាំងអម្បាលម៉ាន។ ត្រង់នេះហើយ អ្នកស្រុកម្នាក់មានសន្ទុះចិត្តថា បើមានគេឲ្យតម្លៃប្រពៃណីគាត់ដូច្នេះ អ្នកស្រុកគួរតែនាំគ្នាស្ទួយអ្វីដែលទើបនឹងលិចទៅឲ្យងើបឡើងវិញ។ ខ្លួនគាត់ផ្ទាល់នឹងឲ្យកូនប្រុសម្នាក់កោរឆ្លងវ័យនេះ ក្រៅអំពីនោះក៏ច្រើនជាសាច់ញាតិគាត់ដែរ ដែលនឹងយកកូនមកកោរ។ តើកោរជុកយ៉ាងម៉េចបើគ្មានក្មេងណាទុកជុកផង? គឺគេនឹងកោរក្បាលក្មេងទាំងនោះ ដោយទុកឲ្យ

[១] ទិន្នន័យច្បាស់ជាងនេះមាននៅ ៖ អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ដឹប, ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ, ហនុមានទេសចរណ៍ ២០០៧។ អាំង ជូលាន, រស់ សុខុម, គង់ វីរៈ, Gens d’Angkor (ភាពយន្តឯកសារ)។

[២] ពាក្យនេះ ធម្មតានិយាយពីព្រះសង្ឃដែលដាច់អប្បជិខុសវិន័យធ្ងន់ធ្ងរ ដូចជាមានស្រីជាដើម។ ក្មេងស្រីដែលបរាជិកដោយកោរពុំទាន់ពេលនោះ បើនៅខេត្តសៀមរាបគេមិនឲ្យធ្វើពិធីអ្វីទេ គឺគេកាត់ផ្តាច់ជុកនោះលើគូថត្បាល់។

[៣] ពាក្យថា "ជុក" នេះខ្ញុំប្រើតាមផ្លូវការទេ។ នៅតំបន់ខាងជើងប្រទេសកម្ពុជាក៏គេស្គាល់ពាក្យនេះដែរ តែគេនិយមថា "កំប៉ោច" (អ្នកភ្នំពេញនិងតំបន់ឯទៀតថា "កំប៉ោយ") ហើយគេច្រើននិយាយថា "កោរសក់" ពុំសូវឮថា "កោរជុក" ឡើយ។

នៅសល់តែកំប៉ោយមួយចំកណ្ដាលក្បាល ឬកំប៉ោយបីជាមុមចង្ក្រាននៅពេលបុណ្យនោះ ហើយតែមួយយប់ ព្រឹកឡើងក៏ផ្ដាច់កំប៉ោយឆ្លងបុណ្យជាស្ថាពរ។ នេះជាករណីទីមួយដែលទាក់ទងនឹងភូមិទំនប់, ឃុំទំនប់, ស្រុកបាធាយ។ សូមបញ្ជាក់ថា អ្នកផ្ដើមនោះធ្លៀតឱកាសធ្វើបុណ្យចាកមហាបង្សុកូលឲ្យឪពុកម្ដាយគាត់ផង ក្រោយពីបានចម្លើយពីអាចារ្យមកថា ពុំមានខុសអ្វីដែរ ព្រោះជាកិច្ចពីរផ្សេងគ្នា, អាចារ្យខុសគ្នា, វណ្ដាប់ខុសគ្នា...។

ដោយសារមានឧទាហរណ៍មួយធ្វើឲ្យមានសន្ទុះចិត្តដូច្នេះ បន្តិចក្រោយមក នៅភូមិចាន់, ឃុំតាំងក្រសាំង, ស្រុកបាធាយដដែល អ្នកស្រុកក៏ស្រុះស្រួលគ្នាធ្វើពិធីឆ្លងវ័យឲ្យក្មេងដូចគ្នានោះដែរ។ ករណីទីពីរនេះខុសពីមុនត្រង់ថា អ្នកផ្ដើមបុណ្យនោះត្រូវធ្វើបុណ្យចាកមហាបង្សុកូលឲ្យឪពុកម្ដាយ ដូច្នោះហើយក៏នឹកឃើញភ្ជាប់ពិធីកោរជុកផង ដោយប្រមូលក្មេងបានដល់ទៅ២១នាក់ មានស្រីមានប្រុស។ ក្នុងចំណោមនោះ មានក្មេងម្នាក់ធ្លាប់ទុកកំប៉ោយដល់អាយុប្រាំឆ្នាំផង តែគេកោរផ្ដាច់ឲ្យប៉ុន្មានឆ្នាំមុននេះដោយគ្មានកិច្ចពិធីអ្វីឡើយ ព្រោះកាលនោះគេយល់ថាអំណើះតទៅលែងមានបុណ្យកោរជុកទៀតហើយ។

ដោយទេសកាលពិសេសនេះហើយបានជាកាលបរិច្ឆេទបុណ្យនៅភូមិចាន់ប្លែកបន្តិច ត្បិតធ្វើនៅថ្ងៃ ៧រោច ខែពិសាខ មិនដូចនៅភូមិទំនប់ដែលធ្វើក្នុងខែផល្គុនតាមធម្មតា។ មើលទៅប្រហែលជាមកអំពីបំណងធំដំបូង គឺធ្វើបុណ្យចាក ព្រោះបុណ្យនេះគេតែងធ្វើខែចេត្រ ឬពិសាខដូច្នេះ។

## ប្រៀបធៀបចំណុចខ្លះនៅឯផ្ទៃពេណីនៅតំបន់អង្គរ

បើពោលសង្ខេបបំផុត ប្រហែលជាអាចថានៅកំពង់ចាម កិច្ចមានតិចជាងនៅតំបន់អង្គរ ហើយក៏ពុំមានន័យថាគេធ្វើកាត់ដែរ គឺប្រហែលជាទំនៀមពីមុនមកដូច្នេះឯង។ បានជាខ្ញុំយល់យ៉ាងនេះ មកពីខ្ញុំយកកិច្ចមួយហៅថា "ដេកអង្កររាប" មកគិត។ ភូមិនៅស្រុកបាធាយនេះ កិច្ចដេកអង្កររាប គេនិយមណាស់ក្នុងពិធីចូលម្លប់[៤]។ ហេតុនេះ ការដែលពុំឃើញមានដេកអង្កររាបនៅពិធីកោរជុក ពុំបានសេចក្ដីថាមកពីគេមិនស្គាល់ឡើយ គឺមកពីប្រពៃណីកោរជុកនៅឯណោះ ពុំដែលមានកិច្ចដេកអង្កររាប។

នៅឯណោះគេមិនធ្វើរានកោរឲ្យមានកំពស់ស្មើ ឬខ្ពស់ជាងផ្ទះដោយមានស្ពានមួយសម្រាប់ដើរឆ្លងទៅទេ គឺកន្លែងអ្វីទានានៅឯដីដាច់ពីផ្ទះទាំងអស់។ គេធ្វើរោងបុណ្យនៅផ្ទាល់ដី។ នៅក្លៀសាន ដាច់ពីផ្ទះនោះ គឺបុស្បុក។ បុស្បុកនេះនៅកណ្ដាលរាជវតិដែលមានទ្វារនៅទិសទាំងបួន (រូបលេខ១១)។ បើគិតជាន័យ គឺភ្នំដែលនៅកណ្ដាលលោក ពោលគឺពុំ

---

[៤]របៀបវាល់អង្ករ ព្រមទាំងឧបករណ៍ដែលយកមកវាល់ មិនដូចគ្នាបេះបិតនឹងតំបន់អង្គរទេ តែគោលការណ៍និងន័យទូទៅពុំខុសគ្នាឡើយ។



រូបលេខ១១



រូបលេខ១២



រូបលេខ១៣

ខុសអ្វីពីរានកោរនៅតំបន់អង្គរឡើយ ថ្វីត្បិតតែបើមើលតែនឹងភ្នែកសុទ្ធ ឃើញប្លែកគ្នាខ្លាំង។ តែបើប្រៀបធៀបទៅកន្លែងធ្វើកិច្ចពេលក្មេងស្រីចេញពីម្លប់នៅតំបន់បាធាយនេះវិញ ឃើញថាមានរបៀបតែមួយ អាចពោលថាដូចគ្នាក៏បាន។ នេះបង្ហាញថាប្រពៃណីរៀបចំកន្លែងធ្វើកិច្ចពិធីជាសុខុមលោកនៅឯណោះ គេធ្វើរបៀបនេះឯង។ ចំពោះកិច្ចវិញ អង្គររាបឥតមានធ្វើដូចទើបនឹងនិយាយមកហើយ។ រីឯកិច្ចសូត្រហៅព្រលឹងពីស្ពានដូចនៅតំបន់អង្គរ ក៏ពុំមានដែរ ប៉ុន្តែនៅខាងចុងពិធី អាចារ្យមានគួចព្រលឹង ដោយយកអំបោះចងដៃក្មេងទាំងនោះដែរ។ ក្រៅអំពីនោះ គ្មានអ្វីខុសគ្នាខ្លាំងគួរឲ្យកត់សម្គាល់ឡើយ ត្បិតធ្វើពីល្ងាចដូចគ្នា, ចាប់ផ្ដើមឡើងដោយសែនក្រុងពាលីដូចគ្នា, ព្រះសង្ឃនិមន្តមកជយន្តោឲ្យពរជ័យក្មេងទាំងនោះដូចគ្នា គ្រាន់តែបង្វិលពពិលនៅឯណោះមិនធ្វើនៅយប់នោះទេ ព្រោះគ្មានសូត្រហៅព្រលឹង ដូច្នេះគេបង្វិលពពិលនៅស្អែកព្រឹកឡើងទៅវិញ (រូបលេខ១២)។ ព្រឹកព្រហាមស្រាងៗ ក្មេងទាំងអស់ទៅសំពះព្រះអាទិត្យដូចគ្នា ហើយកិច្ចធ្វើធ្មេញក៏គ្មានខុសគ្នាអ្វីជាធំដុំឡើយ។ គេនិមន្តព្រះសង្ឃមកកោរបន្តិចបន្តួចឲ្យបានគ្រប់គ្នាជាឧបកិច្ចដែរ នៅក្នុងបុស្បុកនោះ (រូបលេខ១៣) រួចទើបឪម៉ែញាតិមិត្តមកកោរបញ្ចប់។

រីឯរណ្ដាប់នានា ទោះជារូបរាងមិនដូចគ្នាបេះបិតនឹងនៅភូមិតំបន់អង្គរ ក៏គេរៀបចំឡើងក្នុងន័យតែមួយ។ តទៅនេះជាឧទាហរណ៍ខ្លះៗ។ បាយព្រលឹងដែលឃើញនៅលើរូបលេខ១៤ ទីបញ្ចប់ទៅគេបើកបញ្ចុកក្មេងរៀងៗខ្លួនដូចគ្នា។ បាយស្រីដើម (រូបលេខ១៥) ដែលគេរុំស្អាតបាតហើយភ្ជាប់ស្លឹកញ្ចៅនោះ ដល់ទីបញ្ចប់គេហែកបើកឡើងវិញដូចគ្នា តែនៅឯណោះគេហែកយកស្លឹកចេកព្រហ្មចារីយ



រូបលេខ១៤



រូបលេខ១៥

ឲ្យក្មេងបានម្នាក់បន្តិចៗ។ “ព្រះខ័ន” ធ្វើពីស្លឹកត្នោតមានចារពាក្យបាលី ដែលនៅអង្គរគេដាក់គងលើស្មាក្មេងពេលវាក្រាបប្រណម្យព្រះសង្ឃ នៅឯណោះគេហៅ “ដំបងពេជ្រ”។ គេវាន់ពាក់ឈៀងឲ្យក្មេងក្នុងកិច្ចដូចគ្នា (រូបលេខ១៦)។ ម្យ៉ាងទៀតត្រចៀកក្មេង ពុំមែនគ្រាន់តែមានអំបោះក្លុកមកសៀតមួយចំហៀងទេ គឺនៅមួយចំហៀងទៀតមានសៀតស្លឹកញ្ញ ដែលយើងធ្លាប់ដឹងថាជាទំនៀមព្រាហ្មណ៍ដែរ។ ដងថ្លចក៏មានប្រើសម្រាប់ដង្ហែក្មេងដូចគ្នា (រូបលេខ១៧)។

ខ្ញុំគ្មានបំណងរៀបរាប់ប្រៀបធៀបល្អិតល្អន់ទេ ដូចបានពោលមកពីលើរួចហើយ គ្រាន់តែសារុបឲ្យខ្លីមកគឺថា គំនិតជាមូលដ្ឋាននៃកិច្ចព្រមទាំងវណ្ណាប់នានានៅក្នុងពិធីនេះ ពុំមានអ្វីប្លែកពីទំនៀមនៅតំបន់អង្គរឡើយ។ ខ្ញុំធ្វើកំណត់ហេតុយ៉ាងសង្ខេបនេះ ក្នុងគោលបំណងមួយជៀងពោលគឺលើកយករឿងនេះជាប្រធានបទមួយសម្រាប់អ្នកស្រាវជ្រាវសិក្សាអំពីសង្គម ចាប់អារម្មណ៍ ពិចារណាត្រិះរិះវែងឆ្ងាយ ត្បិតករណីដែលហាក់ដូចជាពិសេសនេះ អាចពុំមែនជាពិសេស អ្វីប៉ុន្នានទេក៏មិនដឹង។



រូបលេខ១៦



រូបលេខ១៧

អ្នកអានបានឃើញហើយថាប្រពៃណីមួយដែលហាក់ដូចជាបាត់បង់ជាស្ថាពរមកប្រមាណជិត៤ទសវត្សហើយ ស្រាប់តែត្រដរខ្យល់រករស់ឡើងវិញ។ ប្រការនេះធ្វើឱ្យនឹកដល់ជំនឿអំពីមនុស្ស "ភ្លឹក" ព្រោះធ្លាប់ឮថាមានអ្នកឈឺភ្លឹកដល់ទៅបីថ្ងៃឬមួយអាទិត្យបាត់ស្មារតីអស់ តែខ្លួននៅមានកំដៅ។ គេតែងនិយាយថាព្រលឹងអ្នកនោះធ្វើដំណើរទៅជួបព្រឹត្តិការណ៍ផ្សេងៗ ទាល់តែគ្រូណាពូកែចេះអន្ទងហៅមកវិញបាន ទើបអ្នកឈឺនោះស្វាងជាប្រក្រតីដូចមុន។ ចន្លោះពេលនោះ គ្រួសារញាតិមិត្តជឿថាអ្នកនោះស្លាប់ហើយ គ្រាន់តែពុំទាន់អស់ចិត្ត ដោយឃើញខ្លួននៅក្តៅ ក៏មិនហ៊ានយកទៅបូជា។

ត្រឡប់មកពិធីកោរជុកនៅស្រុកបាធាយវិញ៖ ប្រសិនបើខ្ញុំពុំបានផ្តើះផ្តៀលជម្រុញលើកទឹកចិត្តឱ្យគេធ្វើឡើងវិញ ទំនៀមនេះប្រហែលជាបាត់បង់ជាស្ថាពរមែនហើយ។ តែការផ្តើះផ្តៀលនោះក៏គ្មានអ្វីលើសពីការលើកទឹកចិត្តសសើរដោយស្មោះអំពីការស្រឡាញ់ប្រពៃណីដែរ។ ខ្ញុំពុំមានឱ្យគំនិតថាគួរធ្វើដូច្នេះ ឬដូច្នោះទាល់តែសោះ គឺស្រេចលើអ្នកស្រុកជាម្ចាស់ទំនៀមទាំងស្រុង។

ខ្ញុំនិយាយពីលើបន្តិចមកហើយថា កាលគេសម្រេចថាធ្វើបុណ្យកោរជុកឱ្យក្មេង១១នាក់នៅភូមិទំនប់នោះ គេផ្លៀតបន្ថែមបុណ្យចាកចម្រើនអាយុឱ្យមនុស្សចាស់ទៀត[៥]។ រីឯនៅភូមិចាន់វិញ ប្រហែលជាគម្រោងបុណ្យចាកមានរួចហើយទើបគេសម្រេចបន្ថែមពិធីកោរជុកទៀត ដោយឃើញលទ្ធផលល្អជាក់ស្តែងនៅភូមិទំនប់។ ដូច្នេះជាការយកតម្រាប់តាមអ្វីដែលឃើញថាប្រសើរ ពុំមែនជាការសាកល្បងមុនគេទេ។ ដូច្នេះហើយបានជាកាលបរិច្ឆេទប្លែកបន្តិច ព្រោះធ្វើនៅខែពិសាខ។

ម្យ៉ាងទៀតខ្ញុំបានដំណឹងក្រោយមកថា ៣ថ្ងៃមុនកោរជុកនៅភូមិចាន់ មានភូមិមួយទៀតនៅជិតនោះឈ្មោះភូមិក្រដាស់ (ឃុំតាំងក្រសាំង, ស្រុកបាធាយ) ក៏គេមានភ្ជាប់ពិធីកោរជុកទៅជាមួយបុណ្យបច្ច័យបួនដែរ។ ខ្ញុំមិនបានទៅមើលទេ ដោយមិនបានដឹងមុន តែយ៉ាងណាក៏អាចកាត់យល់ថា សុទ្ធតែយកតម្រាប់តាមភូមិទំនប់ដែលគេយល់ថាជាគម្រូល្អដែរ។

បុណ្យទាំងបីកន្លែងនេះបង្ហាញថាពិធីកោរជុកពុំទាន់ចេញមុខ ដាច់តែឯងសុទ្ធឡើយ ព្រោះយកពិធីមួយទៀតមកឯប (ករណីភូមិទំនប់) ឬទៅឯបជាមួយគេ (ករណីភូមិចាន់ និងភូមិក្រដាស់)។តែទោះបីយ៉ាងណា ក៏ឃើញថាងើបមកវិញដែរ ថ្វីត្បិតតែនៅលីបលនៅឡើយ។ តើទៅអនាគតនិងវិវឌ្ឍយ៉ាងណាទៅទៀត? នេះជាការលំបាកស្មានណាស់។ ឯប្រការដែលឃើញច្បាស់ក្រឡែតនឹងភ្នែកនោះវិញ គឺអ្នកស្រុក តែកាលណាដឹងថាមានអ្នកក្រៅស្រឡាញ់ប្រពៃណីខ្លួនហើយ យ៉ាងហោចណាស់តែងខិតខំធ្វើម្តេច បន្តការប្រតិបត្តិនោះទៅទៀត។

ដែលហៅថាស្រឡាញ់ គឺគោរពមាននៅក្នុងនោះ ពុំមែនការមករើរុះ បញ្ញាតាមសទ្ធាលុយពីក្រៅឡើយ។

[៥] ពិធីចម្រើនអាយុទាំងអម្បាលម៉ានសុទ្ធសឹងជាពិធីឆ្លងវ័យទាំងអស់ទោះជាធ្វើជា "បច្ច័យបួន", "ចន្ទសុកគីរីសូត្រ", "ចាកមហាបង្សុកូល" ក៏និមិត្តរូបមានតែម្យ៉ាងគឺសន្មតថា អ្នកនោះស្លាប់មួយគ្រាសិន ទើបកើតឡើងវិញជាថ្មីទៀត។ តែឆ្លងវ័យប្រភេទនេះ គឺឆ្លងវ័យបញ្ច្រាស ពុំឆ្លងពីក្មេងទៅចាស់ទេ គឺពីចាស់មកក្មេងវិញ។

## សង្ខេប

*ពិធីកោរជុកនៅខេត្តកំពង់ចាម ៖ ដង្ហើមចុងក្រោយត្រដររស់?*

កំណត់ហេតុនេះ ពុំមែនជារបាយការណ៍ពិស្តារអំពីពិធីកោរជុកដែលអ្នកនិពន្ធបានឃើញនៅខេត្តកំពង់ចាម ឡើយ តែជាសេចក្តីសង្ខេបពិធី។ គោលបំណងអ្នកនិពន្ធ គឺចង់ទាញអារម្មណ៍អ្នកស្រាវជ្រាវមកលើបាតុភូតដែលកម្រមានមួយ។ នៅតំបន់ដែលយកមកនិយាយនោះ គេបោះបង់ពិធីកោរជុកចោលជាច្រើនទសវត្សមកហើយ តែទេសកាលពិសេសមួយ, ថាជាការចៃដន្យក៏សឹងបាន, ធ្វើឲ្យគ្រួសារមួយផ្តួចផ្តើមបបួលអ្នកភូមិជាមួយគ្នាធ្វើឡើងវិញ។ លុះឃើញថាបានលទ្ធផលប្រសើរ ភូមិមួយទៀតនៅម្តុំនោះក៏ធ្វើតាម ហើយបានជោគជ័យដូចគ្នា។ នេះជាករណីកម្រមានមួយ ដែលគួរឲ្យសង្គមវិទូជាអាទិ៍យកមកពិចារណាថា ប្រពៃណីមួយដែលស្មានថារលាយអស់ហើយ អាចរស់ឡើងវិញបានឬទេ? បើបាន តើទាល់តែមានកត្តាឬលក្ខណអ្វីខ្លះ?

## Abstract

*The "top-knot cutting" ceremony in Kompong Cham province: the dying breath?*

This note is not a detailed ethnographic report on a pre-puberty ritual recently observed in two villages of Kompong Cham province. The rite of passage in question had been abandoned for four decades without nonetheless having been totally erased from the collective memory. It was nonetheless taken for dead. But, particular circumstances, which arose by accident rather than through a deliberate attempt to revive lost tradition, brought villagers to take certain initiatives to revive the ritual. Given the success of the said revival, a second village took on the same challenge, again with success. The aim of this note is thus to invite scholars to closely examine this sort of relatively rare phenomenon. If the rebirth of this ritual tradition is indeed confirmed in coming years, it would be of interest to pursue research on the minimal conditions required for a moribund tradition, or even one apparently forgotten, to be revived.

## Résumé

*La "tonte de la houppe" dans la province de Kompong Cham : le dernier souffle?*

Cette note n'est pas un rapport ethnographique détaillé sur un rite de pré-puberté récemment observé dans deux villages de la province de Kompong Cham. Ce rite de passage était pourtant abandonné depuis quatre décennies, sans toutefois être totalement effacé de la mémoire collective. On le donnait pour mort, en tout cas. Or des circonstances particulières qui tiennent, à l'origine, plus du hasard que d'une volonté délibérée de rétablir les traditions perdues ont incité un village à prendre des initiatives pour le faire revivre. Au vu du succès obtenu, un deuxième village s'y met à son tour, toujours avec succès. Le but de la note est en quelque sorte une invitation aux chercheurs de suivre de près ce genre de phénomène plutôt rare. Si la renaissance se confirme dans les années qui viennent, il serait en effet intéressant de poursuivre la recherche sur les conditions minimales pour qu'une tradition moribonde, ou même tombée dans l'oubli, revive.